៤.៣. ដេប៉ាតឺម៉ង់ការគ្រប់គ្រងកីឡា (Department of Sport Management)

- ជំនាញការគ្រប់គ្រងកីឡា (Sport Management)

៥. មហាវិទ្យាល័យទេសចរណ៍ និងបដិសណ្ឋារកិច្ច **(Faculty of Tourism and Hospitality)**

៥.១. ដេប៉ាតឺម៉ង់គ្រប់គ្រងទេសចរណ៍ (Department of Tourism Management)

- ជំនាញគ្រប់គ្រងទេសចរណ៍ (Tourism Management)

៥.២. ដេប៉ាតឺម៉ង់គ្រប់គ្រងបដិសណ្ឋារកិច្ច (Department of Hotel Management and Hospitality)

- ជំនាញគ្រប់គ្រងសណ្ឋាគារនិងបដិសណ្ឋារកិច្ច (Hotel Management and Hospitality)

៥.៣. ដេប៉ាតឺម៉ង់ពិពណ៌សេដ្ឋកិច្ច (Department of Exhibition Economy)

- ជំនាញពិពណ៌សេដ្ឋកិច្ច (Exhibition Economy)

ទៅអនាគតសាកលវិទ្យាល័យនេះ អាចបើកសាខា មហាវិទ្យាល័យថ្មី ដេប៉ាតឺម៉ង់ថ្មី មុខជំនាញថ្មី កម្រិតបណ្តុះបណ្តាលថ្មី រៀបចំរចនាសម្ព័ន្ធមហាវិទ្យាល័យ សុំប្តូរឈ្មោះថ្មី ទីតាំងថ្មី ឬពង្រីកទីតាំងថ្មី ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា។

មាត្រា៤.-

ស.ឡ.អ មានក្រុមប្រឹក្សាភិបាលមួយ ដើម្បីត្រួតពិនិត្យនិងសម្រេចលើគោលនយោបាយ ផែនការអភិវឌ្ឍកម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធដទៃទៀត។ តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងជាក់ស្តែងនៃ **ស.ឡ.អ** ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល និងមានការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា។

មាត្រា៥.-

សាកលវិទ្យាធិការនៃ**ស.ឡ.អ** មានភារកិច្ចដូចខាងក្រោម៖

- ទទួលខុសត្រូវចំពោះមុខច្បាប់ក្នុងការគ្រប់គ្រង**ស.ឡ.អ** និងធានាឱ្យមានសុវត្ថិភាពនិងសណ្តាប់ធ្នាប់សង្គម
- ទទួលខុសត្រូវក្នុងការជ្រើសរើសសិស្ស និស្សិតឱ្យចូលរៀន និងការបញ្ចប់ការសិក្សា ស្របតាមបទដ្ឋានកំណត់របស់ក្រសួងអប់រំ យុវជន និងកីឡា
- រៀបចំបង្កើតថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ដែលមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ជាមុនសិនមុននឹងជ្រើសរើសនិស្សិតចូលរៀនឆ្នាំទីមួយ កម្រិតបរិញ្ញាបត្រ
- រៀបចំកម្មវិធីសិក្សាលម្អិតឱ្យស្របតាមលក្ខខណ្ឌនិងបទប្បញ្ញត្តិនៃក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា
- គោរពនិងអនុវត្តតាមបទដ្ឋាននិងគោលការណ៍ណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលកំណត់អំពីសកម្មភាពនៃការធានាគុណភាពអប់រំឧត្តមសិក្សា

- ធ្វើរបាយការណ៍ប្រចាំឆ្នាំអំពីការងារបណ្តុះបណ្តាលជូនក្រសួងអប់រំ យុវជន និងកីឡា នៅក្រោយដំណាច់ឆមាសទី២។

មាត្រា៦.-

និស្សិតដែលបានរៀនចប់តាមកម្មវិធីសិក្សា និងបានទទួលជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាបត្រតាមកម្រិតនិងឯកទេសដែលបានសិក្សា។ សញ្ញាបត្រនេះ ត្រូវផ្តល់ឱ្យដោយ**ស.ឡ.អ** ដោយផ្អែកលើបញ្ជីឈ្មោះនិស្សិតបញ្ចប់ការសិក្សាជាប់ជាស្ថាពរ ដែលមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា។

មាត្រា៧.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៨.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាកលវិទ្យាធិការនៃ**ស.ឡ.អ** ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៩ កើត ខែ ភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ សីហា ឆ្នាំ២០២០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានីភ្នំពេញ
- ដូចមាត្រា ៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៧៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃ ព្រហស្បតិ៍ ០១រោច ខែ បឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៩/០២៥ ចុះថ្ងៃ សុក្រ ០៩រោច ខែ មិគសិរ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ ត្រូវនឹងថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃ សុក្រ ០២កើត ខែ បុស្ស ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៩ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សម្រេច

មាត្រា១.-

ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាចំនួន ២ ៧១២ ៦០០ ០០០ រៀល (ពីរប៊ីលានប្រាំពីររយដប់ពីរលានប្រាំមួយរយពាន់រៀលគត់) ពីជំពូក ២១ (គម្រោងវិនិយោគផ្ទាល់) នៃខ្ទង់ចំណាយមិនទាន់បែងចែក

អចលកម្មរូបី មកជំពូក ២៦ (ការវិនិយោគ) ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រង ឆ្នាំ ២០២០។

មាត្រា២ .-

ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះតាមគណនីនិងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីផ្តល់ជូនក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា សម្រាប់បន្ថែមដើមទុន។

មាត្រា៣ .-

អនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃ ចន្ទ ០១រោច ខែ ផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការផ្ទេរឥណទានថវិកាមកជំពូក ៦៥ (ឧបត្ថម្ភធន) ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទុកជានិរាករណ៍។

មាត្រា៤ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៩កើត ខែ ភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០២០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៣៤ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកំណត់ប្រភេទ បែបបទ និងនីតិវិធីនៃការផ្តល់លិខិតអនុញ្ញាតឬ អាជ្ញាបណ្ណដល់អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្ម តាមប្រព័ន្ធអេឡិចត្រូនិក និងការលើកលែង

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៧ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនិងរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

សម្រេច

ជំពូកទី១

បទប្បញ្ញត្តិទូទៅ

មាត្រា១ .-

អនុក្រឹត្យនេះ កំណត់អំពីការលើកលែង ប្រភេទ បែបបទ និងលក្ខខណ្ឌនៃការផ្តល់លិខិតអនុញ្ញាត អាជ្ញាបណ្ណ និងវិញ្ញាបនបត្រសម្គាល់ទំនុកចិត្តពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ក្នុងគោលបំណងដើម្បីគ្រប់គ្រងប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងជាមួយអន្តរជាតិ។

មាត្រា២ .-

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះរូបវន្តបុគ្គល សហគ្រាសឯកបុគ្គល នីតិបុគ្គល និងសាខាក្រុមហ៊ុនបរទេសដែលធ្វើប្រតិបត្តិការនិងសកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅក្នុងព្រះរាជាណាចក្រកម្ពុជា និង/ឬ ផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកពីព្រះរាជាណាចក្រកម្ពុជាទៅក្រៅប្រទេស ឬពីក្រៅប្រទេសចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា។

មាត្រា៣ .-

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

១. ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក សំដៅដល់សកម្មភាពទិញ លក់ ជួល ផ្លាស់ប្តូរទំនិញឬសេវា ដោយរាប់បញ្ចូលទាំងសកម្មភាពពាណិជ្ជកម្ម និងវេជ្ជប្បវេណីព្រមទាំងសកម្មភាព និងប្រតិបត្តិការនានារបស់រដ្ឋ តាមប្រព័ន្ធអេឡិចត្រូនិក។

២. បុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក សំដៅដល់បុគ្គលដែលប្រើប្រាស់មធ្យោបាយអេឡិចត្រូនិកដើម្បីផ្គត់ផ្គង់ទំនិញនិង/ឬសេវា លើកលែងគ្រឹះស្ថានធានារ៉ាប់រង។

៣. អន្តរការី សំដៅដល់បុគ្គលដែលផ្តល់សេវាផ្ញើ ទទួល បញ្ជូន ឬរក្សាទុកជាបណ្តោះអាសន្នឬជាអចិន្ត្រៃយ៍នូវទំនាក់ទំនងអេឡិចត្រូនិកនោះ ឬផ្តល់សេវាផ្សេងទៀតដែលពាក់ព័ន្ធនឹងការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

៤. បុគ្គលផ្តល់សេវាទូទាត់ សំដៅដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ឬបុគ្គលដទៃទៀតដែលបានទទួលការអនុញ្ញាត ឬអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា ឱ្យធ្វើប្រតិបត្តិការប្រព័ន្ធទូទាត់ ចេញផ្សាយឧបករណ៍ទូទាត់អេឡិចត្រូនិក ឬមធ្យោបាយទូទាត់ជាអេឡិចត្រូនិក ឬធ្វើប្រតិបត្តិការណាដែលត្រូវបានចាត់ទុកថា ជាការផ្តល់ការទូទាត់សងប្រាក់ជាអេឡិចត្រូនិកដល់សាធារណជន។

៥. ប្រព័ន្ធអេឡិចត្រូនិក សំដៅដល់ឧបករណ៍អេឡិចត្រូនិកឬបណ្តុំឧបករណ៍តភ្ជាប់គ្នា ឬទាក់ទងគ្នាតាមរយៈកម្មវិធីអេឡិចត្រូនិក ដែលអាចធ្វើឱ្យដំណើរការជាស្វ័យប្រវត្តិនៃទិន្នន័យ ព័ត៌មាន ឬ ឯកសារ រួមបញ្ចូលទាំងឧបករណ៍អេឡិចត្រូនិកសម្រាប់រក្សាទុកទិន្នន័យ ព័ត៌មាន ឬឯកសារនោះ។

ជំពូកទី២
ស្ថាប័នមានសមត្ថកិច្ច អាជ្ញាបណ្ណ លិខិតអនុញ្ញាត ការលើកលែង និងវិញ្ញាបនបត្រ

មាត្រា៤ .-

១. ក្រសួងពាណិជ្ជកម្ម ជាស្ថាប័នមានសមត្ថកិច្ចក្នុងការគ្រប់គ្រងនិងផ្តល់លិខិតអនុញ្ញាតឬអាជ្ញាបណ្ណដល់អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងវិញ្ញាបនបត្រសម្គាល់ទំនុកចិត្តពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

២. ការរៀបចំគោលនយោបាយនិងយុទ្ធសាស្ត្រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ក្នុងកម្រិតជាតិនិងអន្តរជាតិជាសមត្ថកិច្ចរបស់ក្រសួងពាណិជ្ជកម្មនិងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ដោយធ្វើការសម្របសម្រួលជាមួយនឹងក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធ។

មាត្រា៥ .-

១. អាជ្ញាបណ្ណសម្រាប់ប្រតិបត្តិការផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវផ្តល់ឱ្យនីតិបុគ្គល និង សាខាក្រុមហ៊ុនបរទេសដែលនឹងធ្វើប្រតិបត្តិការនិងសកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដូចខាងក្រោម៖

ក. សេវាគេហទំព័រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

ខ. សេវាថ្នាលពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

គ. សេវាទីផ្សារអនឡាញ។

ឃ. សេវាគេហទំព័រដេញថ្លៃអនឡាញ។

ង. សេវាស្រដៀងគ្នាផ្សេងទៀតដែលផ្តល់តាមរយៈកម្មវិធីកុំព្យូទ័រឬឧបករណ៍វៃឆ្លាតសម្រាប់ការជំរុញធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

២. លិខិតអនុញ្ញាតប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវផ្តល់ឱ្យរូបវន្តបុគ្គលឬសហគ្រាសឯកបុគ្គលដែល នឹងប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្នុងព្រះរាជាណាចក្រកម្ពុជា រួមទាំងរូបវន្តបុគ្គលឬសហគ្រាសឯកបុគ្គល ដែលប្រើប្រាស់បណ្តាញសង្គមឬប្រព័ន្ធអេឡិចត្រូនិកជាមធ្យោបាយក្នុងការផ្គត់ផ្គង់ឬទិញ-លក់ទំនិញ និង/ឬសេវា។

៣. ត្រូវបានលើកលែងការតម្រូវឱ្យស្នើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក ចំពោះរូបវន្ត បុគ្គល ឬសហគ្រាសឯកបុគ្គលដែលធ្វើសកម្មភាពឬប្រតិបត្តិការដូចខាងក្រោម៖

ក. ការផ្សព្វផ្សាយពាណិជ្ជកម្មអំពីទំនិញឬសេវារបស់ខ្លួន រួមបញ្ចូលទាំងការផ្សព្វផ្សាយលក់ទំនិញឬសេវា ដែលមិនមែនជាសំណើបង្កើតកិច្ចសន្យា។

ខ. ការបម្រុងទុកសេវាដែលមិនមានការកក់ប្រាក់ ឬទូទាត់តម្លៃ ដោយអតិថិជនឬអ្នកប្រើប្រាស់។

គ. ការលក់ទំនិញឬសេវារបស់រូបវន្តបុគ្គលឬសហគ្រាសឯកបុគ្គល ដែលមានផលរបរនៅក្រោមកម្រិត ផលរបរជាអ្នកជាប់ពន្ធតូច។

ឃ. ការលក់ទំនិញ ឬសេវាដែលមានលក្ខណៈគ្រួសារ ឬតាមរដូវកាលប្រមូលផល។

ង. ការលក់ទំនិញ ឬសេវាដែលជាស្នាដៃសិល្បៈផ្ទាល់ខ្លួនសុទ្ធសាធ។

ច. ការបង្ហាត់បង្រៀនដោយឯកជនផ្ទាល់ខ្លួន។

ឆ. ការបង្ហាត់បង្រៀន ឬអប់រំអំពីសាសនារបស់រដ្ឋ។

ការបង្ហាត់បង្រៀនដោយសមាគមឬអង្គការមិនមែនរដ្ឋាភិបាល ដែលមិនរកប្រាក់ចំណេញដោយផ្ទាល់ឬប្រយោល និងសកម្មភាពឬប្រតិបត្តិការដោយស្ថាប័នរដ្ឋក្នុងការផ្តល់សេវាសាធារណៈ ក៏ត្រូវបានលើកលែងការតម្រូវឱ្យស្នើសុំលិខិត អនុញ្ញាតផងដែរ។

៤. ក្នុងគោលបំណងស្រង់ទិន្នន័យ និងការពារអ្នកប្រើប្រាស់ បុគ្គលដែលត្រូវបានលើកលែងការតម្រូវឱ្យស្នើសុំ លិខិតអនុញ្ញាត ដូចបានកំណត់ក្នុងកថាខណ្ឌទី៣ខាងលើ ត្រូវជូនដំណឹងមកក្រសួងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក អំពីព័ត៌មានដូចខាងក្រោម៖

ក. ប្រភេទប្រតិបត្តិការ។

ខ. ឈ្មោះអាជីវកម្ម។

គ. មធ្យោបាយអេឡិចត្រូនិកដែលបានប្រើប្រាស់។

ឃ. មធ្យោបាយទូទាត់របស់ខ្លួន។ និង

ង. អត្តសញ្ញាណម្ចាស់ លេខទូរសព្ទ និងអាសយដ្ឋានសម្រាប់ទំនាក់ទំនង។

គំរូលិខិតជូនដំណឹងមានភ្ជាប់ក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

៥. បុគ្គលដែលទទួលបានលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណ ដូចបានកំណត់ក្នុងកថាខណ្ឌទី១ និងទី២ខាងលើ អាចស្នើសុំវិញ្ញាបនបត្រសម្គាល់ទំនុកចិត្តពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅក្រសួងពាណិជ្ជកម្ម ដើម្បីបញ្ជាក់អំពីអនុលោមភាព សុវត្ថិភាព និងទំនុកចិត្ត។

៦. រូបវន្តបុគ្គលឬសហគ្រាសឯកបុគ្គល នីតិបុគ្គល និងសាខាក្រុមហ៊ុនបរទេសដូចបានកំណត់នៅក្នុងកថាខណ្ឌទី១ កថាខណ្ឌទី២ និងកថាខណ្ឌទី៣នៃមាត្រានេះត្រូវស្ថិតក្រោមនីតិវិធីនៃច្បាប់ស្តីពីសារពើពន្ធជាធរមាន។

ជំពូកទី៣
ការផ្តល់លិខិតអនុញ្ញាត អាជ្ញាបណ្ណ ឬវិញ្ញាបនបត្រ ដល់អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

មាត្រា៦ .-

ការផ្តល់លិខិតអនុញ្ញាតប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវបានកំណត់ដូចខាងក្រោម៖

១. រូបវន្តបុគ្គលដែលមានសិទ្ធិស្នើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក លុះត្រាតែទទួលបានលិខិតអនុញ្ញាតប្រកបអាជីវកម្មឬចុះបញ្ជីពាណិជ្ជកម្ម និងបានចុះបញ្ជីពន្ធដារ ស្របតាមបទប្បញ្ញត្តិជាធរមាន។

២. រូបវន្តបុគ្គលដែលបានកំណត់ក្នុងកថាខណ្ឌទី១ខាងលើ ត្រូវស្នើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅក្រសួងពាណិជ្ជកម្ម មុនពេលចាប់ផ្តើមអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

៣. ពេលធ្វើអាជីវកម្ម ត្រូវផ្តល់ព័ត៌មានអប្បបរមា ដូចមានចែងក្នុងកថាខណ្ឌទី១និងទី២នៃមាត្រា២៩នៃច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក នៃព្រះរាជាណាចក្រកម្ពុជា។

៤. សុពលភាពនៃលិខិតអនុញ្ញាតប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក មានរយៈពេល២(ពីរ)ឆ្នាំ គិតចាប់ពីថ្ងៃផ្តល់លិខិតអនុញ្ញាតដោយក្រសួងពាណិជ្ជកម្ម ហើយអាចស្នើសុំបន្តសុពលភាពបាន។

៥. បែបបទ ឯកសារតម្រូវ ការបន្តសុពលភាព ការកែប្រែព័ត៌មាន និងលក្ខខណ្ឌក្នុងការផ្ទេរលិខិតអនុញ្ញាត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

មាត្រា៧ .-

១. នីតិបុគ្គលឬសាខាក្រុមហ៊ុនបរទេស ដែលជាអន្តរការីឬបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវស្នើសុំអាជ្ញាបណ្ណសម្រាប់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅក្រសួងពាណិជ្ជកម្ម មុនពេលចាប់ផ្តើមប្រតិបត្តិការ ហើយត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

ក. បានចុះបញ្ជីពាណិជ្ជកម្ម និងចុះបញ្ជីពន្ធដារក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ហើយមានកម្មវត្ថុអាជីវកម្មសម្រាប់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

ខ. មានវិញ្ញាបនបត្រសេវាអនឡាញ និងឈ្មោះដែនកម្មសិទ្ធិពីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

គ. ប្រើមធ្យោបាយឬកម្មវិធីអេឡិចត្រូនិក សម្រាប់ធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

ឃ. ប្រព័ន្ធអេឡិចត្រូនិកដែលនឹងត្រូវបានប្រើប្រាស់ ត្រូវមានសុក្រឹត្យភាពដូចមានកំណត់ក្នុងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

ង. មានការបញ្ជាក់អំពីមធ្យោបាយទូទាត់។

ច. មានគំរូអាជីវកម្មនិងទម្រង់នៃកិច្ចការពារអ្នកប្រើប្រាស់។

ឆ. ក្នុងករណីនីតិបុគ្គលឬសាខាក្រុមហ៊ុនបរទេសដែលជាអន្តរការី ត្រូវធ្វើកិច្ចសន្យាជាមួយបុគ្គលផ្តល់សេវាពាណិជ្ជកម្ម អំពីការតម្រូវឱ្យផ្តល់ព័ត៌មានអប្បបរមា អនុលោមតាមកថាខណ្ឌទី១និងទី២នៃមាត្រា ២៩ និងមាត្រា៣៣នៃច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក នៃព្រះរាជាណាចក្រកម្ពុជា។

២. សុពលភាពនៃអាជ្ញាបណ្ណសម្រាប់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មានរយៈពេល៣(បី)ឆ្នាំ គិតចាប់ពីថ្ងៃផ្តល់អាជ្ញាបណ្ណដោយក្រសួងពាណិជ្ជកម្ម ហើយអាចស្នើសុំបន្តសុពលភាពបាន។

៣. បែបបទ ឯកសារតម្រូវ ការបន្តសុពលភាព ការកែប្រែព័ត៌មាន និងលក្ខខណ្ឌក្នុងការផ្ទេរអាជ្ញាបណ្ណ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

មាត្រា៨ .-

១. អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលទទួលបានលិខិតអនុញ្ញាតប្រកបអាជីវកម្មឬអាជ្ញាបណ្ណសម្រាប់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិករួចហើយ អាចស្នើសុំវិញ្ញាបនបត្រសម្គាល់ទំនុកចិត្តពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកពីក្រសួងពាណិជ្ជកម្ម តាមការស្ម័គ្រចិត្ត។

២. បែបបទ ឯកសារតម្រូវ លក្ខណៈវិនិច្ឆ័យ កម្រិតអនុលោមភាពនៃគោលការណ៍ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

មាត្រា៩ .-

បែបបទនិងនីតិវិធីនៃការព្រមានជាលាយលក្ខណ៍អក្សរ ការបញ្ឈប់សកម្មភាពឬប្រតិបត្តិការអាជីវកម្ម ការព្យួរ ការដកហូត ឬការលុបចោលលិខិតអនុញ្ញាតឬអាជ្ញាបណ្ណ ត្រូវកំណត់ដោយប្រកាសរួមរវាងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

ជំពូកទី៤
អន្តរប្បញ្ញត្តិ

មាត្រា១០ .-

រូបវន្តបុគ្គល សហគ្រាសឯកបុគ្គល នីតិបុគ្គល ឬសាខាក្រុមហ៊ុនបរទេស ដែលបានធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមុនអនុក្រឹត្យនេះចូលជាធរមាន ត្រូវស្នើសុំលិខិតអនុញ្ញាតឬអាជ្ញាបណ្ណ ដូចបានកំណត់ក្នុងជំពូកទី៣ នៃអនុក្រឹត្យនេះ ក្នុងរយៈពេលយ៉ាងយូរបំផុត៦(ប្រាំមួយ)ខែ ក្រោយពេលអនុក្រឹត្យនេះចូលជាធរមាន។

ជំពូកទី៥
អវសានប្បញ្ញត្តិ

មាត្រា១១ .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងខ្លឹមសារនៃអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា១២ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៩កើត ខែ ភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ សីហា ឆ្នាំ២០២០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម	**រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**
ប៉ាន សូរស័ក្តិ	**ជា វ៉ាន់ដេត**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៣៦ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សានីតិកម្ម និងយុត្តិធម៌ នៃក្រសួងយុត្តិធម៌

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ២៤០ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

សម្រេច

ជំពូកទី១
បទប្បញ្ញត្តិទូទៅ

មាត្រា១ .-

ត្រូវបានបង្កើតក្រុមប្រឹក្សានីតិកម្ម និងយុត្តិធម៌ សរសេរជាអក្សរកាត់ថា "**ក.ន.យ**" ជាអង្គភាពនៅអមក្រសួងយុត្តិធម៌ ដើម្បីជាសេនាធិការក្នុងការពិនិត្យ សិក្សា ស្រាវជ្រាវ និងផ្តល់យោបល់លើវិស័យច្បាប់ និងវិស័យយុត្តិធម៌ដល់ក្រសួងយុត្តិធម៌ ក្នុងគោលបំណងដើម្បីធានាប្រសិទ្ធភាព សង្គតិភាព និងអនុលោមភាពគតិយុត្ត ក្នុងការរៀបចំ និងតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាដែលជាសមត្ថកិច្ចរបស់ក្រសួងយុត្តិធម៌ ក៏ដូចជាដើម្បីលើកកម្ពស់ប្រសិទ្ធភាពក្នុងការអនុវត្តការងារ និងអភិបាលកិច្ចល្អ ក្នុងវិស័យយុត្តិធម៌។

ជំពូកទី២
តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សានីតិកម្ម និងយុត្តិធម៌

មាត្រា២ .-

ក.ន.យ. មានតួនាទី និងភារកិច្ច ដូចតទៅ៖

- ផ្តល់យោបល់ផ្នែកច្បាប់ ក្នុងការរៀបចំ និងតាក់តែងសេចក្តីព្រាងច្បាប់ និងសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តនានា ដែលជាសមត្ថកិច្ចរបស់ក្រសួងយុត្តិធម៌ ដើម្បីធានាបានសង្គតិភាព និងអនុលោមភាពគតិយុត្តជាមួយនិងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- សិក្សា ស្រាវជ្រាវ និងផ្តល់យោបល់ជូនក្រសួងយុត្តិធម៌ ទាក់ទងនឹងប្រសិទ្ធភាពនៃការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាដែលត្រូវបានដាក់ឱ្យអនុវត្តក្នុងវិស័យយុត្តិធម៌
- សិក្សា ស្រាវជ្រាវ និងផ្តល់យោបល់ជូនក្រសួងយុត្តិធម៌ ទាក់ទងនឹងសង្គតិភាព និងអនុលោមភាពគតិយុត្តរវាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាក្នុងវិស័យយុត្តិធម៌ ព្រមទាំងសង្គតិភាព និងអនុលោមភាពគតិយុត្តរវាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តក្នុងវិស័យយុត្តិធម៌ ជាមួយនិងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត
- សិក្សា ស្រាវជ្រាវ និងផ្តល់យោបល់ជូនក្រសួងយុត្តិធម៌ ក្នុងការរៀបចំ និងតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលចាំបាច់សម្រាប់បម្រើឱ្យវិស័យយុត្តិធម៌
- ចូលរួមសហការតាមការចាំបាច់ជាមួយនិងអង្គភាពជំនាញនានារបស់ក្រសួងយុត្តិធម៌ ដើម្បីផ្សព្វផ្សាយ និងបណ្តុះបណ្តាលច្បាប់ដល់មន្ត្រីតុលាការ និងមន្ត្រីអនុវត្តច្បាប់ពាក់ព័ន្ធ សំដៅបង្កើនប្រសិទ្ធភាពនៃការគោរពច្បាប់ និងអនុវត្តច្បាប់
- ចូលរួមសហការតាមការចាំបាច់ ជាមួយនិងអង្គភាពជំនាញនានារបស់ក្រសួងយុត្តិធម៌ ដើម្បីផ្សព្វផ្សាយច្បាប់ តាមរយៈការរៀបចំចងក្រងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាក្នុងវិស័យយុត្តិធម៌ ក៏ដូចជាការរៀបចំ និងបោះពុម្ពផ្សាយព្រឹត្តបត្រច្បាប់ ជាដើម
- សិក្សា ស្រាវជ្រាវ និងផ្តល់យោបល់ជូនក្រសួងយុត្តិធម៌ ដើម្បីលើកកម្ពស់ប្រសិទ្ធភាព និងគុណភាពនៃការផ្តល់សេវាយុត្តិធម៌ ក៏ដូចជាកិច្ចដំណើរការនៃសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការចាំបាច់នៅក្នុងវិស័យយុត្តិធម៌
- សិក្សា ស្រាវជ្រាវ និងផ្តល់យោបល់ជូនក្រសួងយុត្តិធម៌ អំពីភាពចាំបាច់នានាសម្រាប់ការរៀបចំ និងការអនុវត្តគោលនយោបាយ និងកម្មវិធីកែទម្រង់ក្នុងវិស័យយុត្តិធម៌
- អនុវត្តការងារផ្សេងទៀត តាមការប្រគល់ភារកិច្ចរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

ជំពូកទី៣
សមាសភាពរបស់ក្រុមប្រឹក្សានីតិកម្ម និងយុត្តិធម៌

មាត្រា៣ .-

ក.ន.យ. ដឹកនាំដោយប្រធានមួយរូប ដោយមានអនុប្រធាន និងសមាជិកមួយចំនួន សម្រាប់ជួយបំពេញការងារ ដែលត្រូវតែងតាំង និងបញ្ចប់មុខតំណែងដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី តាមសេចក្តីស្នើសុំពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

ប្រធាន អនុប្រធាន និងសមាជិករបស់ **ក.ន.យ.** ត្រូវជ្រើសរើសចេញពីចំណោមបញ្ញវន្តដែលមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រឡើងទៅ ខាងផ្នែកនីតិសាស្ត្រ រដ្ឋបាលសាធារណៈ វិទ្យាសាស្ត្រនយោបាយ ឬ វិទ្យាសាស្ត្រសង្គម និងមានបទពិសោធន៍ការងារយ៉ាងតិច ៥ (ប្រាំ) ឆ្នាំ ក្នុងវិស័យច្បាប់ ឬវិស័យយុត្តិធម៌។

ជំពូកទី៤
កិច្ចដំណើរការរបស់ក្រុមប្រឹក្សានីតិកម្ម និងយុត្តិធម៌

មាត្រា៤ .-

អនុប្រធាន និងសមាជិក **ក.ន.យ.** ត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញរបស់ប្រធាន។ ក្នុងករណីអវត្តមាន ឬមានធុរៈ ប្រធានអាចប្រគល់សិទ្ធិជូនអនុប្រធាន ១ (មួយ) រូប ឱ្យកោះអញ្ជើញ និងដឹកនាំកិច្ចប្រជុំតាមការចាំបាច់។

ក.ន.យ. មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងយុត្តិធម៌ ក្នុងការបំពេញការងាររបស់ខ្លួន។

មាត្រា៥ .-

ក.ន.យ. មានសិទ្ធិអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ ព្រមទាំងថៅក្រម និងព្រះរាជអាជ្ញា ឬស្នើសុំអ្នកជំនាញផ្នែកច្បាប់ផ្សេងៗ ពីស្ថាប័នឯកជន ឬស្ថាប័នផ្សេងៗទៀតរបស់រាជរដ្ឋាភិបាល ដើម្បីចូលរួមផ្តល់យោបល់ក្នុងកិច្ចប្រជុំរបស់ខ្លួន។

មាត្រា៦ .-

ក.ន.យ. អាចមានទីប្រឹក្សា និងជំនួយការមួយចំនួនតាមការចាំបាច់។

ទីប្រឹក្សា និងជំនួយការ ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ឬអនុក្រឹត្យ។

មាត្រា៧ .-

ក.ន.យ. មានលេខាធិការដ្ឋានមួយ ថ្នាក់ស្មើនាយកដ្ឋានចំណុះក្រសួងយុត្តិធម៌ ជាសេនាធិការក្នុងការបំពេញមុខងាររបស់ខ្លួន។

លេខាធិការដ្ឋាន **ក.ន.យ.** ដឹកនាំដោយប្រធានមួយរូប មានឋានៈ និងបុព្វសិទ្ធិស្មើប្រធាននាយកដ្ឋាន ដែលត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងអមដោយអនុប្រធានមួយចំនួន មានឋានៈ និងបុព្វសិទ្ធិស្មើអនុប្រធាននាយកដ្ឋាន ដែលត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន **ក.ន.យ.** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

ជំពូកទី៥
ប្រភពធនធានរបស់ក្រុមប្រឹក្សានីតិកម្ម និងយុត្តិធម៌

មាត្រា៨ .-

ក.ន.យ. មានប្រភពធនធាន ផ្គត់ផ្គង់ដោយថវិកាជាតិ នៅក្នុងក្របខណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួងយុត្តិធម៌។

ក.ន.យ. មានសិទ្ធិទទួលធនធាន និងថវិកាពីប្រភពផ្សេងៗទៀតសម្រាប់ដំណើរការការងាររបស់ខ្លួន ស្របតាមច្បាប់និងនីតិវិធីជាធរមាន។

ជំពូកទី៦
អវសានប្បញ្ញត្តិ

មាត្រា៩ .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា១០ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១០ កើត ខែ ភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ២០២០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

កើត រិទ្ធ

កន្លែងទទួល៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦៧៦ អនក្រ.តត

អនុក្រឹត្យ

ស្តីពី

ការតែងតាំងក្រុមប្រឹក្សាភិបាលអគ្គិសនីកម្ពុជា សម្រាប់អាណត្តិទី៨

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣៩៦/១០ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតអគ្គិសនីកម្ពុជា ជាក្រុមហ៊ុនទទួលខុសត្រូវមានកំណត់មួយរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ២៣ អនក្រ.បក ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៩៦ ស្តីពីការកំណត់ពីទំនាក់ទំនងរវាងរាជរដ្ឋាភិបាលនិងអគ្គិសនីកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៤១ អនក្រ.បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តន៍ព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

សម្រេច

មាត្រា១ .–

ត្រូវបានតែងតាំងក្រុមប្រឹក្សាភិបាលអគ្គិសនីកម្ពុជា សម្រាប់អាណត្តិទី៨ (២០២០-២០២៣) ដែលមានសមាសភាពដូចខាងក្រោម៖

១- ឯកឧត្តម	**កែវ រតនៈ**	រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកអគ្គិសនីកម្ពុជា
២- ឯកឧត្តម	**ហែម ក្រាញ់តូនី**	រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី
៣- ឯកឧត្តម	**ចាន់ សុធី**	រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
៤- ឯកឧត្តម	**ទិចច័រ ហ្សូនា**	អគ្គនាយកនៃអគ្គនាយកដ្ឋានថាមពល ក្រសួងរ៉ែនិងថាមពល
៥- លោក	**គី ខេមលីន**	អគ្គនាយករងនៃអគ្គនាយកដ្ឋានស្រាវជ្រាវនិងអភិវឌ្ឍន៍លើវិស័យយុត្តិធម៌ ក្រសួងយុត្តិធម៌
៦- លោកស្រី	**សុខ សុឆ្វាទី**	ប្រធានរដ្ឋបាលសភាពាណិជ្ជកម្មកម្ពុជា។

មាត្រា២ .–

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៣ .–

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១១រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០២០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦៧៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការបញ្ចប់តួនាទីមន្ត្រីការទូតជាន់ខ្ពស់ប្រចាំស្ថានតំណាង នៃព្រះរាជាណាចក្រកម្ពុជានៅបរទេស

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានឃើញអនុក្រឹត្យលេខ ២៧៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការគ្រប់គ្រង និងការកំណត់បៀវត្សប្រចាំខែ និងការឧបត្ថម្ភផ្សេងៗសម្រាប់មន្ត្រីរាជការ និងបុគ្គលិកបំពេញភារកិច្ចតាមស្ថានតំណាងកម្ពុជានៅបរទេស
- បានឃើញអនុក្រឹត្យលេខ ១០៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

សម្រេច

មាត្រា១: ត្រូវបានបញ្ចប់តួនាទីលោកស្រី **រស់ សេរី** ជាអគ្គទីប្រឹក្សា នៃស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំព្រះរាជាណាចក្រថៃឡង់ដ៍ ដោយសាមីខ្លួនទទួលមរណភាព។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១២រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ ២០២០ ✓

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦៧៨ អនក្រ.តត

អនុក្រឹត្យ

ស្តីពី

ការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : តែងតាំងលោក **ខាន់ សុខា** ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ៦ ឱ្យកាន់មុខតំណែងជាអភិបាលរង នៃគណៈអភិបាលខេត្តតាកែវ សម្រាប់អាណត្តិទី២ ក្នុងដែនសមត្ថកិច្ចដដែល។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ១៥រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០២០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៦៧៩ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការអនុវត្តវិន័យមន្ត្រីនគរបាលជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ស ម្រេ ច

មាត្រា ១: ត្រូវបានដកហូតឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** ពីវរសេនីយ៍ឯក **ជា សុផាណារ៉ា** អត្តលេខ ០៦៥១៩ នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

មាត្រា ២: បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ ចន្ទ ១៥ រោច ខែ អាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ២០២០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៦៥០ អនក្រ.តត

អនុក្រឹត្យ
ស្តីពី
ការតែងតាំងមុខតំណែង នាយទាហាន

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទី ភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំង របស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

សម្រេច

មាត្រា១ : តែងតាំងមុខតំណែង នាយទាហាននៃកងយោធពលខេមរភូមិន្ទ ជូនឧត្តមនាវីត្រី **ជុំ សុផល** អត្តលេខ០១៤៩៨៤ ជា ស្នងការ ស្នងការដ្ឋានប្រតិបត្តិការសឹក បញ្ជាការដ្ឋានកងទ័ពជើងទឹក ។

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី គ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ ចន្ទ ១៥ រោច ខែ អាសាឍ ឆ្នាំ ជូត ទោស័ក ព.ស ២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០២០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួលៈ
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៦៤១ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយសុវត្ថារា
រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

សម្រេច

មាត្រា១.-បំពាក់មេដាយ**សុវត្ថារា** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ ចំនួន២៣៨រូប នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិ នាពេលកន្លងមក ដូចមានរាយនាមខាងក្រោម៖

ក-មេដាយ **សុវត្ថារា** ថ្នាក់ **ធិបឌិន្ទ**

១-លោកស្រី	អយ ទូច	អនុប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តព្រះវិហារ
២-លោកស្រី	ជា កញ្ញា	អនុប្រធានការិយាល័យរដ្ឋបាល នៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា
៣-លោក	ស្រី សុធារិទ្ធ	ប្រធានដេប៉ាតឺម៉ង់ព័ត៌មានវិទ្យា នៃវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម
៤-លោក	ម៉េង លាភ	អនុប្រធានកសិដ្ឋានផលិតពូជស្រូវទួលសំរោង នៃអគ្គនាយកដ្ឋានកសិកម្ម
៥-លោក	អ៊ិច សុធី	អនុប្រធាននាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យ នៃអគ្គនាយកដ្ឋានកសិកម្ម
៦-លោកស្រី	ប៊ុល សាធនី	ប្រធានការិយាល័យរដ្ឋបាល ផែនការ គណនេយ្យ និងសហប្រតិបត្តិការអន្តរជាតិ នៃអគ្គនាយកដ្ឋានកសិកម្ម

៧-លោកស្រី	គង់ សុផា	អនុប្រធានការិយាល័យរដ្ឋបាល ផែនការ គណនេយ្យ និងសហប្រតិបត្តិការអន្តរជាតិ នៃអគ្គនាយកដ្ឋានកសិកម្ម
៨-លោកស្រី	រស់ គីម	អនុប្រធានការិយាល័យកិច្ចការរដ្ឋបាល និងនីតិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម
៩-លោក	នេន ចំរើន	ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តព្រះសីហនុ
១០-លោក	ឈន លក	ប្រធានការិយាល័យអភិវឌ្ឍន៍សហគមន៍កសិកម្ម នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីភ្នំពេញ
១១-លោក	ព្រឿង សុឃៀង	នាយរងខណ្ឌរដ្ឋបាលព្រៃឈើបាត់ដំបង នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តបាត់ដំបង
១២-លោកស្រី	ព្រុំ ធីតា	ប្រធានការិយាល័យសវនកម្មទី១ នៃនាយកដ្ឋានសវនកម្មផ្ទៃក្នុង
១៣-លោក	ស៊ិន ទ្រី	ប្រធានការិយាល័យប្រព័ន្ធកសិកម្មនិងសេដ្ឋកិច្ចកសិកម្ម នៃនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
១៤-លោក	លី ឡា	នាយខណ្ឌរដ្ឋបាលជលផលកំពង់ឆ្នាំង នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ឆ្នាំង
១៥-លោក	ជា សុខុន	អនុប្រធាននាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
១៦-លោក	ហេង ម៉ូរ៉ានី	អគ្គនាយករង នៃអគ្គនាយកដ្ឋានសុខភាព និងផលិតកម្មសត្វ
១៧-លោក	នូ វនិកា	ប្រធាននាយកដ្ឋានសុខភាពសត្វ និងសុខភាពសាធារណៈបសុព្យាបាល នៃអគ្គនាយកដ្ឋាន សុខភាពសត្វ និងផលិតកម្មសត្វ
១៨-លោក	ពេជ្រ ប៉េដា	អនុប្រធាននាយកដ្ឋានសុខភាពសត្វ និងសុខភាពសាធារណៈបសុព្យាបាល នៃអគ្គនាយកដ្ឋាន សុខភាពសត្វ និងផលិតកម្មសត្វ
១៩-លោក	ខេង ស៊ីម	អនុប្រធានការិយាល័យគណនេយ្យ នៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
២០-លោក	ស៊ិន បូ	មន្ត្រីខណ្ឌរដ្ឋបាលព្រៃឈើក្រចេះ នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តក្រចេះ
២១-លោក	ស្រី សាវ៉ែន	អនុប្រធានការិយាល័យសម្របសម្រួល តាមដាន និងវាយតម្លៃ នៃនាយកដ្ឋានផែនការ និងស្ថិតិ
២២-លោក	នាង សាក់	ប្រធានការិយាល័យ នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តស្វាយរៀង
២៣-លោក	បូយ ឡូត	ប្រធានការិយាល័យរដ្ឋបាល បុគ្គលិក នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តព្រៃវែង
២៤-លោក	នាង សុទ្ធប៊ុណារិទ្ធ	អធិការ នៃអគ្គាធិការដ្ឋាន
២៥-លោក	ម៉ៅ សុវឌ្ឍន៍	អធិការ នៃអាគ្គាធិការដ្ឋាន
២៦-លោក	ថាយ សុមុនី	ប្រធាននាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម នៃរដ្ឋបាលជលផល
២៧-លោក	អ៊ិន ហ៊ុល	អនុប្រធាននាយកដ្ឋានអភិរក្សជលផល នៃរដ្ឋបាលជលផល
២៨-លោក	សុង ប្រុស	ប្រធានការិយាល័យរដ្ឋបាល នៃវិទ្យាស្ថានជាតិកសិកម្មព្រែកលៀប
២៩-លោកស្រី	គីម ប៉ុណ្ណារី	ប្រធានការិយាល័យរដ្ឋបាលបុគ្គលិក នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកណ្តាល
៣០-លោក	គ្រី ថាន់នី	មន្ត្រីការិយាល័យផលិតកម្ម និងបសុព្យាបាល នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកណ្តាល

៣១-លោក	លី ម៉េងស៊ាង	ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ចម្ការព្រៃដាំនិងព្រៃឯកជន នៃរដ្ឋបាលព្រៃឈើ
៣២-លោកស្រី	អ៊ឹម ម៉ារ៉ឺឌី	ប្រធានការិយាល័យសហគមន៍ព្រៃឈើ នៃរដ្ឋបាលព្រៃឈើ
៣៣-លោកស្រី	ប្រាជ្ញ ច័ន្ទម៉ាលី	អនុប្រធានការិយាល័យកិច្ចការព្រៃឈើ នៃរដ្ឋបាលព្រៃឈើ
៣៤-លោកស្រី	យី សុផាន់ណា	អនុប្រធានការិយាល័យនីតិកម្ម និងវិវាទ នៃរដ្ឋបាលព្រៃឈើ
៣៥-លោកស្រី	ប៉ែន ឡៃយឹង	អនុប្រធានការិយាល័យរដ្ឋបាល និងផែនការ នៃរដ្ឋបាលព្រៃឈើ
៣៦-លោក	បេង ឆាំ	នាយខណ្ឌរដ្ឋបាលជលផលប៉ៃលិន នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តប៉ៃលិន
៣៧-លោកស្រី	យួន គឹមលីន	មន្ត្រីការិយាល័យគ្រប់គ្រងបុគ្គលិក នៃនាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស

ខ-មេដាយ **សុវត្ថារា** ថ្នាក់ **សេនា**

១-លោក	នួន សុខុម	នាយខណ្ឌរដ្ឋបាលព្រៃឈើព្រះវិហារ នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តព្រះវិហារ
២-លោក	ផេន ភារុន	ប្រធានការិយាល័យសរីរវិទ្យា នៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា
៣-លោក	ហាក់ ប៊ុនធួន	នាយករង នៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា
៤-លោកស្រី	អៀង ស៊ីធី	អនុប្រធានការិយាល័យគណនេយ្យ នៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា
៥-លោក	រ័ត្ន សុភព្វ	មន្ត្រីដេប៉ាតឺម៉ង់ វិទ្យាសាស្ត្រ និងវេជ្ជសាស្ត្រសត្វ នៃវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម
៦-លោក	សោម សាវី	ប្រធានអង្គភាពលទ្ធកម្ម នៃវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម
៧-លោក	គង់ គា	ប្រធាននាយកដ្ឋានដំណាំស្រូវ នៃអគ្គនាយកដ្ឋានកសិកម្ម
៨-លោក	អ៊ិន ចាន់ថា	អនុប្រធាននាយកដ្ឋានដំណាំឧស្សាហកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម
៩-លោក	យ៉ិន ច័ន្ទសុធី	អនុប្រធាននាយកដ្ឋានដំណាំឧស្សាហកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម
១០-លោក	ជី ណូរុំ	ប្រធានការិយាល័យរដ្ឋបាល ផែនការ គណនេយ្យ និងសហប្រតិបត្តិការអន្តរជាតិ នៃអគ្គនាយកដ្ឋានកសិកម្ម
១១-លោក	អែម មេត្តា	អនុប្រធានមន្ទីរពិសោធន៍ដី និងជី នៃអគ្គនាយកដ្ឋានកសិកម្ម
១២-លោកស្រី	វង្ស ផល្លា	អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម
១៣-លោក	សេង វណ្ណា	អនុប្រធានស្ថានីយព្ធជបន្លែក្បាលកោះ នៃអគ្គនាយកដ្ឋានកសិកម្ម
១៤-លោក	ស៊ឹម បូរ៉ាមី	ប្រធានការិយាល័យនីតិកម្ម និងដោះស្រាយវិវាទសហគមន៍កសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម
១៥-លោក	សូរ ថាវរិទ្ធិ	ប្រធានការិយាល័យស្រាវជ្រាវអភិវឌ្ឍន៍បច្ចេកវិទ្យាការពារដំណាំ និងវិនិច្ឆ័យសមាសភាពចង្រៃ នៃអគ្គនាយកដ្ឋានកសិកម្ម
១៦-លោក	សរ ចាន់សុធី	អនុប្រធានការិយាល័យស្រាវជ្រាវអភិវឌ្ឍន៍បច្ចេកវិទ្យាការពារដំណាំ និងវិនិច្ឆ័យសមាសភាពចង្រៃ នៃអគ្គនាយកដ្ឋានកសិកម្ម
១៧-លោក	គឹម ស្មឿន	អនុប្រធានការិយាល័យភូតគាមអនាម័យ នៃអគ្គនាយកដ្ឋានកសិកម្ម
១៨-លោក	ជៀម ឈាងលីម	អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
១៩-លោកស្រី	ពៅ វណ្ណនី	អនុប្រធានការិយាល័យអាស៊ានកសិកម្ម នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ

២០-លោក	យស់ ចន្ថាណា	អនុប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តព្រះសីហនុ
២១-លោក	មាស ពិសិដ្ឋ	អនុប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្ទឹងត្រែង
២២-លោក	អន ច័ន្ទសុជាតិ	នាយរងខណ្ឌព្រៃឈើស្ទឹងត្រែង នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្ទឹងត្រែង
២៣-លោក	លី គន	នាយផ្នែករដ្ឋបាលព្រៃឈើស្ទឹងត្រែង នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្ទឹងត្រែង
២៤-លោក	ម៉ា រ៉ា	នាយផ្នែករដ្ឋបាលព្រៃឈើសៀមប៉ាង នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្ទឹងត្រែង
២៥-លោក	ជាម យូដុង	នាយរងខណ្ឌរដ្ឋបាលព្រៃឈើស្ទឹងត្រែង នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្ទឹងត្រែង
២៦-លោក	ឯម សំអាត	នាយសង្កាត់រដ្ឋបាលព្រៃឈើត្រាំកក់ នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តតាកែវ
២៧-លោក	អ៊ុក ស៊ីថាច	អនុប្រធានការិយាល័យផែនការ គណនេយ្យ នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តរតនគិរី
២៨-លោក	ប៊ិន ធារង្ស	នាយរងខណ្ឌរដ្ឋបាលជលផលរតនគិរី នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តរតនគិរី
២៩-លោក	ឆៃ ពេជ្រ	អនុប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ស្ពឺ
៣០-លោក	អ៊ឹង រដ្ឋវិបុល	ប្រធានការិយាល័យកសិ-ឧស្សាហកម្ម នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីភ្នំពេញ
៣១-លោក	ប៉ុក វីរៈ	ប្រធានការិយាល័យរដ្ឋបាល បុគ្គលិក នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីភ្នំពេញ
៣២-លោក	យ៉ាន់ ពៅ	ប្រធានការិយាល័យផលិតកម្ម និងបសុព្យាបាល នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីភ្នំពេញ
៣៣-លោក	ខន ខែម	នាយផ្នែករដ្ឋបាលព្រៃឈើសំរោង នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តឧត្តរមានជ័យ
៣៤-លោក	ឃ្លិន រ៉េត	នាយរងសង្កាត់រដ្ឋបាលព្រៃឈើសំរោង-ចុងកាល់ នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តឧត្តរមានជ័យ
៣៥-លោក	ជាន ទូច	ប្រធានការិយាល័យអប់រំនិងផ្សព្វផ្សាយកសិកម្ម នៃនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
៣៦-លោក	ឆាយ មន	នាយរងខណ្ឌរដ្ឋបាលជលផលពោធិ៍សាត់ នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តពោធិ៍សាត់
៣៧-លោក	ស៊ិន សុផល្លា	មន្ត្រីខណ្ឌរដ្ឋបាលព្រៃឈើពោធិ៍សាត់ នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តពោធិ៍សាត់
៣៨-លោក	តាក់ សីហាក់	នាយផ្នែករដ្ឋបាលជលផលផ្សារឆ្នាំង នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ឆ្នាំង

៣៩-លោក	អ៊ុំ ច្រូយ	នាយសង្កាត់រដ្ឋបាលព្រៃឈើសាមគ្គីមានជ័យ នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ឆ្នាំង
៤០-លោក	លឹម សុធី	មន្ត្រីការិយាល័យផែនការ គណនេយ្យ នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តសៀមរាប
៤១-លោក	អ៊ីវ បូរី	មន្ត្រីការិយាល័យផលិតកម្ម និងបសុព្យាបាល នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តសៀមរាប
៤២-លោក	អាំង សុខផល	ប្រធានការិយាល័យគ្រឿងយន្តកសិកម្ម នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តសៀមរាប
